# ដាក់ពាក្យធ្វើពន្ធដើម្បីបានប្រាក់ដែលអ្នកត្រូវបានមកវិញ

អ្នកអាចមានសិទ្ធិទទួលបានប្រាក់រហូតដល់ទៅ **$6,000** ឬច្រើនជាងនេះ ដែលានមកពីប្រាក់ពន្ធដែលរដ្ឋសងមកឱ្យអ្នកវិញ  នៅពេលណាដែលអ្នកដាក់សុំឥណទានពន្ធលើប្រាក់ចំណូល ដែលអ្នករកបាន និងប្រាក់ឥណទានសំរាប់កូន

## 1 ដើម្បីរកកន្លែងជួយធ្វើពន្ធឱ្យដោយឥតគិតថ្លៃ*

ចូលទៅវ៉ិបសាយ **irs.treasury.gov/freetaxprep** ឬទូរស័ព្ទទៅលេខ **800-906-9887** ។

## 2 ដើម្បីឱ្យដឹងថាតើអ្នកមានសិទ្ធិទទួលប្រាក់មកវិញដែរទេ

ដើម្បីចង់ដឹងថាតើអ្នកប្រហែលជាអាចទទួលបានប្រាក់សងមកវិញប៉ុន្មានដែរ សូមចូលទៅ **eitcoutreach.org/help** ។

## 3 សូមដាក់ពាក្យធ្វើពន្ធ

ចូរទៅកន្លែងជួយធ្វើពន្ធឱ្យដោយឥតគិតថ្លៃ ឱ្យបានមុនថ្ងៃទី 15 ខែ មេសា ដើម្បីដាក់ពាក្យធ្វើពន្ធរបស់អ្នក និង ទទួលបានប្រាក់របស់អ្នកមកវិញ នៅពេលធ្វើពន្ធ ។

* អ្នកនៅតែអាចដាក់ពាក្យសុំឥណទានពន្ធបាន ទោះបើជាអ្នកមិនអាចរកកន្លែងដែលជួយធ្វើពន្ធឱ្យបានដោយឥតគិតថ្លៃ នៅក្បែរអ្នកក៏ដោយ ។

### *នៅពេលណាដែលអ្នកនឹងត្រូវដាក់ពាក្យធ្វើពន្ធរបស់អ្នក?*

Date: Time:

Location: Phone:

សំរាប់ពត៌មានបន្ថែម, សូមចូលទៅ **eitcoutreach.org/help** ឬទូរស័ព្ទទៅក្រសួង IRS តាមរយៈលេខ **1-800-829-1040** ។

GET IT BACK CB

# តើខ្ញុំមានសិទ្ធិដែរឬទេ?

ឥណទានពន្ធលើប្រាក់ចំណូលដែលរកបានពីកន្លែងធ្វើការ និងឥណទានពន្ធសំរាប់កូន គឺជាលុយសងសំរាប់អ្នកដែលធ្វើការ ។ អ្នកអាចបង់ពន្ធឱ្យរដ្ឋវិញតិច ឬទទួលបានប្រាក់សងមកវិញ។

*ការដាក់ពាក្យសុំឥណទានទាំងនេះនឹងមិនប៉ះពាល់ដល់សិទ្ធិទទួលជំនួយ ឬ ជំនួយទាំងឡាយណា ដូចជាជំនួយ SNAP (ម្ហូប) អេសអេសអាយ មេឌីខេដ ជំនួយជាលុយ ឬជំនួយបង់ថ្លៃផ្ទះសាធារណៈនោះទេ ។ ប្រសិនបើអ្នកសន្សំប្រាក់សំណងពេលធ្វើពន្ធរបស់អ្នក ប្រាក់នោះនឹងមិនត្រូវបានគេ រាប់ជាប្រាក់ចំណូល នៅក្នុងកម្មវិធីផ្តល់ជំនួយពីសហពន្ធ័ នៅពេលគណនាកំណត់ធនធាន/ទ្រព្យសម្បត្តិ សំរាប់ក្នុងរយៈពេល 12 ខែ ក្រោយពេលដែលអ្នក បានទទួលប្រាក់សំណងនោះ ។*

## ប្រសិនបើអ្នកមានកូន

☐ **អាយុ:** សំរាប់ *EITC* កូនត្រូវតែមានអាយុក្រោម 19 ឆ្នាំ គិតត្រឹមចុងឆ្នាំ 2019 (បើជាកូនសិស្ស រៀនពេញម៉ោង អាចមានអាយុក្រោម 24 ឆ្នាំ ហើយបើជាកូនដែលពិការតែម្តង នោះអាចមានអាយុប៉ុន្មានក៏បានដែរ) ។ សំរាប់ *CTC*, កូនត្រូវតែមានអាយុក្រោម 17 ឆ្នាំ គិតត្រឹមចុងឆ្នាំ 2019 ។

☐ **ទីកន្លែងរស់នៅ:** កូនត្រូវតែបានរស់នៅជាមួយអ្នកលើសពីកន្លះឆ្នាំ ក្នុងឆ្នាំ 2019 ។

☐ **ប្រាក់ចំណូលសំរាប់ឆ្នាំ 2019:** សំរាប់ *CTC* ប្រសិនបើអ្នករកចំណូលបានច្រើនជាង $2,500 អ្នកអាចដាក់ពាក្យធ្វើពន្ធ ហើយអាចទទួលបានលុយមកវិញរហូតដល់ $2,000 សំរាប់កូនម្នាក់ៗ ។

| ចំនួនកូន | នៅលីវ | រៀបការ | EITC បាន រហូតដល់ |
|---|---|---|---|
| 1 | $41,094 | $46,884 | $3,526 |
| 2 | $46,703 | $52,493 | $5,828 |
| 3 ឬលើសពីនេះ | $50,162 | $55,952 | $6,557 |

### *តើត្រូវយកឯកសារអ្វីទៅកន្លែងធ្វើពន្ធដោយឥតគិតថ្លៃ*

- ប័ណ្ណសំគាល់ខ្លួនដែលមានសុពលភាព
- ប័ណ្ណសូស្យាល់សេគ្យួរិទី លិខិតបញ្ជាក់លេខសូស្យាល់សេគ្យួរិទី ឬ លេខ ITIN
- W-2 ឬ បែបបទលេខ 1099
- បែបបទលេខ 1095-A

## ប្រសិនបើអ្នកមិនមានកូន

☐ **អាយុ:** អ្នកត្រូវតែមានអាយុចន្លោះរវាង 25 ឆ្នាំ ទៅ 64 ឆ្នាំ ។

☐ **ប្រាក់ចំណូលសំរាប់ឆ្នាំ 2019:** ប្រសិនបើអ្នករកប្រាក់ចំណូលបានតិចជាង $15,570 ($21,370 ប្រសិនបើដាក់ថារៀបការ) អ្នកអាចទទួលបាន លុយសងសំរាប់ EITC រហូតដល់ $529 ។

## ប្រសិនបើអ្នកមិនមានសញ្ជាតិអាមេរិកាំង

☐ **EITC:** ទាំងរូបអ្នក គ្រួសារអ្នក និងកូនអ្នក ត្រូវតែមានលេខសូស្យាល់សេគ្យួរិទីដែលមានសុពលភាព ទើបធ្វើពន្ធបាន។

☐ **CTC:** ទាំងរូបអ្នក និងប្តី ប្រពន្ធអ្នក ត្រូវតែមានលេខសូស្យាល់សេគ្យួរិទី ឬ លេខសំគាល់សំរាប់អ្នកបង់ពន្ធ (ITIN) ទើបធ្វើពន្ធបាន។ កូនដែលអ្នកដាក់ឈ្មោះធ្វើពន្ធ ត្រូវតែមានលេខសូស្យាល់សេគ្យួរិទី។

## កិច្ចធានារ៉ាប់រងសុខភាព

អ្នកប្រហែលជាមានសិទ្ធិអាចទទួលបានកិច្ចធានារ៉ាប់រងសុខភាពដោយឥតគិតថ្លៃ ឬក្នុងតម្លៃថោក ជាមួយមេឌីខេដ ឬ បានឥណទានពន្ធក៏រីតខ្ពស់ ។ ចូរចុះឈ្មោះក្នុងកម្មវិធីមេឌីខេដនៅពេលណាក៏បានដែរ ឬចុះឈ្មោះតាម **HealthCare.gov** ចាប់ពីរវាង ថ្ងៃទី 1 ខែ វិច្ឆិកា ឆ្នាំ 2019 រហូតដល់ថ្ងៃទី 15 ខែធ្នូ ឆ្នាំ 2019 ។ ទទួលបានពតិមានបន្ថែម តាមរយៈលេខ **1-800-318-2596** ឬ **www.HealthCare.gov**។